THE SCHOOL DISTRICT OF PHILADELPHIA

**អង្គភាពប្រតិបត្តិការ**
440 North Broad Street
Philadelphia, PA 19130

3 កុម្ភៈ 2021

ជូនចំពោះក្រុមគ្រួសាររបស់មណ្ឌលសិក្សាធិការ School District of Philadelphia ជាទីរាប់អាន

ស្របពេលដែលការជួសជុល និងការកែលម្អការបន្សុទ្ធខ្យល់ត្រូវបានធ្វើឡើងនៅក្នុងសាលារៀនរបស់យើង របាយការណ៍នៃការបន្សុទ្ធខ្យល់តាមកម្រិតសាលារៀនដែលត្រូវបានបង្ហោះអនឡាញនៅទីនេះ នឹងផ្លាស់ប្តូរ។ អ្នកធ្វើតុល្យភាពខ្យល់ដែលមានសញ្ញាបត្របញ្ជាក់កំពុងធ្វើតេស្តឡើងវិញលើតំបន់ដែលទទួលរងឥទ្ធិពល និងធ្វើបច្ចុប្បន្នភាពរបាយការណ៍នៃការបន្សុទ្ធខ្យល់នៅពេលដែលមានលទ្ធផលថ្មីៗ។ ហេតុដូច្នេះហើយទើបសាលារៀនមួយចំនួនដែលពីមុនគ្មានកម្រិតបរិមាណផ្ទុកចំនួនមនុស្សនៅក្នុងបន្ទប់មួយចំនួន ឥឡូវនេះមានអត្រាលំហូរខ្យល់ និងបរិមាណផ្ទុកចំនួនមនុស្សខ្ពស់។

ទាំងនេះគ្រាន់តែជាឧទាហរណ៍មួយចំនួននៃការងារដែលបានបញ្ចប់ដោយជោគជ័យក្នុងរយៈពេលពីរបីថ្ងៃកន្លងមក ដើម្បីទ្រទ្រង់ដល់លំហូរខ្យល់បរិសុទ្ធនៅក្នុងសាលារៀនខណៈពេលដែលយើងរៀបចំដើម្បីស្វាគមន៍បុគ្គលិក និងសិស្សត្រឡប់មកវិញប្រកបដោយសុវត្ថិភាពក្នុងដំណាក់កាលសម្រាប់ការត្រឡប់ទៅបង្រៀន និងចូលរៀននៅសាលារៀនវិញ៖

- នៅសាលា General Philip Kearny School កង្ហារមេកានិចជាប់ពិដានផ្ទះដែលផ្តល់នូវការបន្សុទ្ធខ្យល់នៅគ្រប់ជ្រុងជ្រោយនៃសាលារៀនត្រូវបានអនុម័ត ដែលធ្វើឲ្យវាដំណើរការពេញលេញដោយមិនចាំបាច់មានកង្ហារជាប់បង្អួចទេ។ ការធ្វើតេស្តតុល្យភាពខ្យល់ត្រូវបានអនុវត្តនៅក្នុងបន្ទប់នីមួយៗ ហើយរបាយការណ៍ដែលបានធ្វើបច្ចុប្បន្នភាពនឹងអាចប្រើប្រាស់បានក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខទៀត។
- ប្រព័ន្ធ HVAC ត្រូវបានជួសជុលយ៉ាងពេញលេញនៅសាលា Joseph W. Catharine School ដូច្នេះកង្ហារជាប់បង្អួចលែងមានភាពចាំបាច់តទៅទៀតហើយ។ បន្ទប់ដែលពីមុនគ្មាន ឬមានបរិមាណផ្ទុកចំនួនមនុស្សតិចត្រូវបានគេធ្វើតេស្តឡើងវិញ ហើយរបាយការណ៍ដែលបានធ្វើបច្ចុប្បន្នភាពកំពុងត្រូវបានបង្កើត។
- អ្នកម៉ៅការបានបញ្ចប់ការជួសជុលការបន្សុទ្ធខ្យល់នៅឯ South Philadelphia HS ហើយបានអនុម័តជូននូវកង្ហារបញ្ចេញខ្យល់ធំមួយដែលទ្រទ្រង់ដល់ផ្លូវដើរនៅក្នុងសាលារៀន។
- នៅ Comegys និង Pollock, កង្ហារខ្យល់តាមអគារត្រូវបានគេកែសម្រួលនៅក្នុងថ្នាក់រៀនដើម្បីបង្កើនចរន្តខ្យល់បរិសុទ្ធ។ ការធ្វើតេស្តតុល្យភាពខ្យល់ជាថ្មីត្រូវបានអនុវត្តដើម្បីធ្វើបច្ចុប្បន្នភាពកម្រិតបរិមាណផ្ទុកចំនួនមនុស្ស ហើយរបាយការណ៍នឹងត្រូវបានបង្ហោះក្នុងសប្តាហ៍នេះ។

THE SCHOOL DISTRICT OF PHILADELPHIA

**អង្គភាពប្រតិបត្តិការ**
440 North Broad Street
Philadelphia, PA 19130

សូមចងចាំថាការបន្សុទ្ធខ្យល់ដែលសមស្របនៅតែបន្តជាផ្នែកមួយនៃកម្រិតសុវត្ថិភាពមួយក្នុងចំណោមកម្រិតសុវត្ថិភាពផ្សេងៗទៀតដែលនឹងត្រូវបានដំឡើងនៅគ្រប់អគារនៃមណ្ឌលសិក្សាធិការរបស់យើង ខណៈពេលដែលយើងរៀបចំឲ្យសិស្សត្រឡប់មកចូលរៀននៅសាលារៀនវិញបណ្តើរៗ និងដោយសុវត្ថិភាព។ ក្រសួងសុខាភិបាលនៃក្រុង Pennsylvania និងក្រុង Philadelphia និងមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ បានធ្វើការសង្កត់ធ្ងន់យ៉ាងជាប់លាប់អំពីសារៈសំខាន់នៃការដាក់ចេញនូវកម្រិតសុវត្ថិភាពជាច្រើនកម្រិត -- ដូចជាការតម្រូវឲ្យពាក់ម៉ាស់ ការរក្សាគម្លាតសង្គម និងការលាងដៃឲ្យបានញឹកញាប់ -- ដើម្បីការពារសុខភាព និងសុខុមាលភាពរបស់មនុស្សគ្រប់គ្នាក្នុងអំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ។ វិទ្យាសាស្ត្របានបញ្ជាក់ច្បាស់។ នៅពេលដែលកម្រិតសុវត្ថិភាពទាំងនេះត្រូវបានដាក់ចេញ ហានិភ័យនៃការចម្លងនៅក្នុងសាលារៀនគឺទាបណាស់។

ដើម្បីស្វែងយល់បន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងរបស់យើងស្តីពីការបន្សុទ្ធខ្យល់ និងផែនការសុខភាពនិងសុវត្ថិភាពរបស់យើងទាំងអស់ សូមចូលទៅកាន់គេហទំព័រ www.philasd.org/aes។

*ក្រុមការងារប្រតិបត្តិការ SDP*